

ក្រសួងកិច្ចការនារី

# សេដ្ឋកិច្ច

## ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី

## ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា

២០១៤

រូបភាពគំរបមុខ

**ផុន សៀងខេង (៤១ឆ្នាំ)** ជាអាជីវករលក់ដូរនៅផ្សារថ្មីនាទីក្រុងភ្នំពេញ ។ អ្នកស្រី ខេង ប្រកបរបរលក់គ្រឿងសមុទ្រនេះជិត១៥ឆ្នាំមកហើយ ។

## ជំពូកទី ៣

# សេដ្ឋកិច្ច

## ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី

### បរិបទគោលនយោបាយ

ការសម្រេចបានសមភាពយេនឌ័រ គឺជាផ្នែកមួយនៃយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៣ (២០១៤-២០១៨) ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។ រាជរដ្ឋាភិបាល បានផ្តោតជាសំខាន់លើការបង្កើន ការចូលរួមរបស់ស្ត្រី ដើម្បីពន្លឿនការសម្រេចគោលដៅជាតិ ដូចជា ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងចំណែកស្មើភាពសម្រាប់ស្ត្រី ។

ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី មានគោលបំណងបង្កើតឱកាសរកប្រាក់ចំណូលសម្រាប់ស្ត្រី តាមរយៈការលើកកំពស់ការងារដែលមានប្រាក់កម្រៃសមរម្យ និងការអភិវឌ្ឍន៍សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម។

ការបង្កើតឱកាសសេដ្ឋកិច្ចប្រកបដោយនិរន្តភាពរួមទាំងកំណើនប្រាក់ចំណូល និងកម្មសិទ្ធលើទ្រព្យសម្បត្តិត្រូវបានរំពឹងទុកថានឹងកាត់បន្ថយនូវភាពងាយរងគ្រោះរបស់ស្ត្រី ដូចជាការជួញដូរមនុស្ស ការធ្វើទេសន្តប្រវេសន៍មិនស្របច្បាប់ និងអំពើហិង្សាក្នុងគ្រួសារផងដែរ ។

នៅពេលប្រាក់ចំណូលមានការកើនឡើង ស្ត្រីអាចវិនិយោគទៅលើការអវិឌ្ឍន៍ជីវភាពរស់នៅ និងចូលរួមលើការអភិវឌ្ឍន៍ភូមិឃុំប្រកបដោយនិរន្តភាព ។

ដូចនេះ ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី តម្រូវឲ្យមានក្របខ័ណ្ឌគោលនយោបាយចំនួនបួន ដែលទាក់ទងនឹងការងារមានប្រាក់កម្រៃ ការអភិវឌ្ឍន៍សហគ្រាសខ្នាត



ប្រជាជនគ្រប់អាយុប្រកបរបរមានការកើនឡើងយ៉ាងឆាប់រហ័ស

មីក្រូ តូច និងមធ្យម ការធ្វើទេសន្តប្រវេសន៍ និងការអភិវឌ្ឍន៍ជីវភាពរស់នៅទីជនបទ៖

១. នៅប្រទេសកម្ពុជា ការអភិវឌ្ឍន៍ទីផ្សារពលកម្មគឺជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណ ដែលចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីនដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ការងារមានប្រាក់កម្រៃ និងកិច្ចគាំពារសង្គមសម្រាប់កម្មករ កម្មការិនី ត្រូវបានអនុវត្តយោងទៅតាមច្បាប់ការងារ និងអនុសញ្ញាអន្តរជាតិនានា។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានតួនាទីក្នុងការអនុវត្តន៍ច្បាប់ការងារនេះ។

២. ការលើកកំពស់ការអភិវឌ្ឍន៍សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម គឺជាភារកិច្ចរបស់ក្រសួងពាក់ព័ន្ធ។ កិច្ចសន្ទនារវាងវិស័យសាធារណៈ និងឯកជនគឺជាយុទ្ធសាស្ត្រមួយ ដើម្បីបង្កើតឲ្យមានបរិយាកាស

អាជីវកម្មដ៏មានលក្ខណៈអំណោយផលសម្រាប់សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម និងការផ្តល់សេវាហិរញ្ញវត្ថុ។

៣. មានច្បាប់ជាតិមួយចំនួនពាក់ព័ន្ធនឹងការធ្វើទេសន្តប្រវេសន៍ ដើម្បីស្វែងរកការងារ ហើយច្បាប់ទាំងនោះត្រូវបានកែសម្រួល និងផ្តល់ជាគោលការណ៍សម្រាប់ក្រុមហ៊ុនជ្រើសរើសពលករ មជ្ឈមណ្ឌល បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងនីតិវិធីបណ្តឹង។

៤. ការអភិវឌ្ឍន៍ជីវភាពរស់នៅពាក់ព័ន្ធភាគច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាន អាហារូបត្ថម្ភ អនាម័យ និងសកម្មភាពសេដ្ឋកិច្ចតូចៗ។ ការងារទាំងអស់នេះភាគច្រើនជាបន្ទុករបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ។ គោលនយោបាយសម្រាប់ " កែលម្អជីវភាពរស់នៅនៅតាមសហគមន៍ជនបទ ជាពិសេសសម្រាប់ស្ត្រីក្រីក្រ " ត្រូវបានបញ្ជាក់នៅក្នុងក្របខ័ណ្ឌអាទិភាពជាតិរយៈពេលមធ្យមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

យុទ្ធសាស្រ្តផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៃក្រសួងកិច្ចការនារី នឹងគាំទ្រ និងចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយខាងលើ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើស្ត្រី។

## ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី សំដៅលើ៖

(១) ការផ្តល់ឱកាសឱ្យស្ត្រីចូលរួមនៅក្នុងសកម្មភាពកសិកម្ម និងសកម្មភាពអភិវឌ្ឍន៍ជីវភាពរស់នៅទីជនបទ ការអភិវឌ្ឍន៍អាជីវកម្ម និងការងារមានប្រាក់កម្រៃ

(២) ស្ត្រីទទួលបានអត្ថប្រយោជន៍ពីឱកាសទាំងនេះ តាមរយៈការផលិត ប្រាក់ចំណូល និងបៀវត្សរ៍ពលកម្ម

(៣) ការផ្តល់ឱកាសឱ្យស្ត្រីមានតួនាទីក្នុងការធ្វើសេចក្តីសម្រេច។ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចពុំទាន់អាចធានាឱ្យមានសមភាពយេនឌ័រឡើយ ប៉ុន្តែបានផ្តល់នូវយន្តការមួយដ៏សំខាន់សម្រាប់ស្ត្រីក្នុងការចរចា ដើម្បីធ្វើឱ្យសុខុមាលភាពស្ត្រីមានភាពប្រសើរឡើង។ ការបន្តផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងកម្រិតទាប អាចបណ្តាលឱ្យសក្តានុពលកំណើនសេដ្ឋកិច្ចកម្ពុជាមានការធ្លាក់ចុះ។ ផ្ទុយទៅវិញ ការកើនឡើងនៃការចូលរួម ការទទួលបានអត្ថប្រយោជន៍ និងការធ្វើសេចក្តីសម្រេច

របស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច នឹងកាត់បន្ថយវិសមភាពនិងជំរុញកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា។

# របកគំហើញ

## និន្នាការសំខាន់ៗនៅក្នុងការអភិវឌ្ឍន៍វិស័យសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម និងកម្លាំងពលកម្ម

ទោះបីជាអត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រី ដែលមានអាយុពី១៥ទៅ៦៤ឆ្នាំ មានការកើនឡើងពី៧៦ទៅ៨០% នៅចន្លោះឆ្នាំ២០០៨ និងឆ្នាំ២០១២ក៏ដោយ ក៏វិសមភាពយេនឌ័រនៅក្នុងការងារមានប្រាក់កម្រៃនៅតែមានគម្លាត។ គម្លាតយេនឌ័រមានការកើនឡើងក្នុងការងារដែលងាយរងគ្រោះ និងការងារក្នុងវិស័យកសិកម្ម[1]។ នេះបង្ហាញឱ្យឃើញថា ស្ត្រីមានឱកាសតិចតួចនៅក្នុងការងារដែលមានផលិតភាពខ្ពស់ និងការងារសមរម្យ ។

## ការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ច

ស្ត្រីចំនួន៤៩% បានចូលរួមក្នុងកម្លាំងពលកម្មសរុបក្នុងឆ្នាំ២០១២ ដែលអត្រានៃកម្លាំងពលកម្មស្ត្រីមាន៨០% និងអត្រាកម្លាំងពលកម្មបុរសមាន៨៩% ក្នុងក្រុមមនុស្សអាយុពី១៥ ទៅ៦៤ឆ្នាំ។ អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ស្ត្រីវ័យក្មេង អាយុពី១៥ទៅ១៩ឆ្នាំ មាន៦៦% ច្រើនជាងអត្រាចូលរួមកម្លាំងពលកម្មរបស់បុរសដែលមានត្រឹមតែ៦៤%។ ចំណុចនេះស្របទៅនឹងការរកឃើញដែលបង្ហាញថា ស្ត្រីទំនងជាបានចូលរៀនតិចជាងបុរសនៅចន្លោះអាយុនេះ[2]។ នៅភ្នំពេញ អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ក្មេងស្ត្រី និងក្មេងប្រុសអាយុពី១៥ទៅ១៩ឆ្នាំ មានភាពខុសគ្នា ដោយក្មេងស្រីមានដល់៤៣% និងក្មេងប្រុសមាន ៣៧%។ ការចូលរួមរបស់ស្ត្រីកម្ពុជាក្នុងកម្លាំងពលកម្មមានអត្រាខ្ពស់ជាងប្រទេសជិតខាង ប៉ុន្តែឱកាសការងារភាគច្រើនងាយរងគ្រោះ និងទទួលបានប្រាក់ចំណូលទាបជាងបុរស ដោយសារតែអត្រាអក្ខរកម្មមានកម្រិតទាប[3]។

---

1 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០០៨ និងឆ្នាំ២០១២) អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ភ្នំពេញ កម្ពុជា
2 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១២) អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ភ្នំពេញ កម្ពុជា
3 អង្គការពលកម្មអន្តរជាតិ សូចនាករទីផ្សារពលកម្មសំខាន់ៗ បោះពុម្ពលើកទី៨

## អត្ថប្រយោជន៍របស់ស្ត្រីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច

ទោះបីជាការចូលរួមនៅក្នុងសេដ្ឋកិច្ចមានកម្រិតខ្ពស់ក៏ប៉ុន្តែស្ត្រីទទួលបានអត្ថប្រយោជន៍តិចជាងបុរស។ ស្ត្រីប្រមាណ៧០% មានការងារធ្វើ ធៀបនឹងបុរសមានត្រឹមតែ៥៩% ប៉ុន្តែការងារទាំងនោះស្ថិតក្នុងភាពងាយរងគ្រោះដូចជាការងារមិនមានប្រាក់កម្រៃនៅក្នុងគ្រួសារ និងការប្រកបរបរអាជីវកម្មខ្លួនឯង[4]។ ការងាររបស់ស្ត្រីផ្តោតសំខាន់លើវិស័យចំនួនបីគឺ៖(១) វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២) ពាណិជ្ជកម្ម និងសេវាកម្ម (៣) ផលិតកម្ម[5]។ ការងារនេះស្មើនឹង៨៩%នៃការងារទាំងអស់របស់ស្ត្រីនៅក្នុងវិស័យសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម។ សហគ្រាសភាគច្រើនជារបស់ស្ត្រី ប៉ុន្តែភាគច្រើនមានលក្ខណៈក្រៅផ្លូវការ និងបានចូលរួមតិចតួចក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចទូទៅ។

## សម្លេងរបស់ស្ត្រី និងសិទ្ធិក្នុងការធ្វើសេចក្តីសម្រេច

ស្ត្រីមានលទ្ធភាពតិចជាងបុរសក្នុងការទទួលបានការងារមានជំនាញខ្ពស់ ការងារក្នុងវិស័យសាធារណៈ ការចូលរួមក្នុងសមាគមអាជីវកម្ម ព្រមទាំងបណ្តាញទំនាក់ទំនងនានាដែលផ្តល់ឱកាសក្នុងការទទួលបានតួនាទី និងការធ្វើសេចក្តីសម្រេច ។ ការបែងចែកការងារសម្រាប់ស្ត្រីនិងបុរស មានភាពខុសប្លែកគ្នាខ្លាំង ដោយស្ត្រីនៅតែបន្តប្រមូលផ្តុំក្នុងការងារមានជំនាញទាប។ ក្នុងឆ្នាំ២០១២ ស្ត្រីតិចជាង៤% (ធៀបនឹងបុរស៦%) បានបម្រើការងារក្នុងមុខតំណែងខ្ពស់ចំនួនបីសំខាន់ៗ៖ ជាអ្នកគ្រប់គ្រង អ្នកជំនាញការ និងអ្នកជំនាញបច្ចេកទេស[6]។នៅក្នុងរដ្ឋបាលសាធារណៈផលធៀបរវាងបុរសនិងស្ត្រីមានប្រមាណជិត៥,៥ នៅក្នុងឆ្នាំ២០១៣[7] (សូមមើលសេចក្តីសង្ខេបសម្រាប់គោលនយោបាយស្តីពី ការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ)។

---

4 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១២) អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ភ្នំពេញ កម្ពុជា
5 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១៣) អង្កេតប្រជាសាស្ត្រចន្លោះជំរឿនកម្ពុជា ភ្នំពេញ កម្ពុជា
6 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១២) អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ភ្នំពេញ កម្ពុជា
7 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១៣) អង្កេតប្រជាសាស្ត្រចន្លោះជំរឿនកម្ពុជា ភ្នំពេញ កម្ពុជា



▲ ជំនួញភាគច្រើនជារបស់ស្ត្រី ប៉ុន្តែជំនួញទាំងនោះគឺជាសហគ្រាសខ្នាតតូច និងមិនផ្លូវការ

## បញ្ហាប្រឈម

### ការងារមានប្រាក់កម្រៃសម្រាប់ស្ត្រី

*ការងារមានប្រាក់កម្រៃផ្តល់ឱកាសជាច្រើនសម្រាប់ស្ត្រី ប៉ុន្តែនៅមានឧបសគ្គដោយសារប្រាក់បៀវត្សរ៍ទាប លក្ខខណ្ឌការងារមិនអំណោយផល ចំនួនប្រជាពលរដ្ឋដែលឈានចូលក្នុងទីផ្សារការងារជារៀងរាល់ឆ្នាំ និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន*

ការងារមានប្រាក់កម្រៃមានចំនួន៣០% នៃការងាររបស់ស្ត្រីក្នុងឆ្នាំ២០១២ ធៀបនឹងការងាររបស់បុរសមាន៤១% (អាយុពី១៥-៦៤ឆ្នាំ)[8]។ ការងារមានប្រាក់កម្រៃបានប្រមូលផ្តុំក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងការផលិតស្បែកជើង ដែលជួយឱ្យស្ត្រីអាយុពី១៥ឆ្នាំឡើងចំនួន៥០០ពាន់នាក់ មានការងារធ្វើ ដែលស្មើនឹង៥៨% នៃការងារឧស្សាហកម្ម និង១៥%នៃ

8 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១២) អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ភ្នំពេញ កម្ពុជា

ការងារសុបសម្រាប់ស្ត្រី[9]។ កម្មករកាត់ដេរភាគ ច្រើនគឺជាស្ត្រីវ័យក្មេង ដែលធ្វើចំណាក ស្រុកពីតំបន់ជនបទ។ បើទោះបីជាមានការអនុលោមតាមច្បាប់ការងារ ដែលជំរុញដោយ អង្គការពលកម្មអន្តរជាតិ (ILO) តាមរយៈ*គម្រោងរោងចក្រកាន់តែប្រសើរនៅ កម្ពុជា* (BFC) ក៏ល័ក្ខខ័ណ្ឌការងារនៅតែមិនទាន់មានភាពល្អប្រសើរនៅឡើយ។ ផលិតភាព ពលកម្មមាន ការកើនឡើងទ្វេរដងពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១២ ប៉ុន្តែប្រាក់កម្រៃអប្បរមា នៅថេរដដែល (ហើយធ្លាក់ចុះក្នុងបរិបទជាក់ស្តែង) រហូតដល់ខែមករា ឆ្នាំ២០១៤ ទើបកើនឡើងដល់១០០ដុល្លាក្នុងមួយខែ។ ក្នុងចំណោមកម្មករមានប្រាក់កម្រៃទាំងអស់ ជាមធ្យមស្ត្រីអាចរកប្រាក់កម្រៃបាន៨១% នៃប្រាក់កម្រៃរបស់បុរស [10]។ ការងារដែលមាន ប្រាក់កម្រៃក្នុងវិស័យកាត់ដេរ ផ្តល់ប្រាក់កម្រៃតិចសម្រាប់ស្ត្រីបើធៀបនឹងប្រាក់ កម្រៃដែល រកបានដោយស្ត្រីក្នុងវិស័យផ្សេងៗទៀត។

ឧបសគ្គចម្បងៗរបស់ស្ត្រីក្នុងការចូលរួមនិងទទួលបានអត្ថប្រយោជន៍ពីការងារមាន ប្រាក់កម្រៃរួមមាន៖ (១) ការអប់រំមានកម្រិតទាប និងអក្ខរកម្ម (២) ប្រាក់កម្រៃ អប្បបរមាទាប (៣)ការរើសអើងក្នុងការងារ ដូចជាកិច្ចសន្យាការងារដែលមានរយៈពេល ខ្លីជាច្រើន។

ស្ត្រីក៏ជួបការលំបាកដោយសារភាពទន់ខ្សោយផ្នែកច្បាប់ការងារ ដូចជាកង្វះភាពជាក់ លាក់នៃការផ្តល់ប្រាក់កម្រៃស្មើគ្នាចំពោះការងារដែលទាមទារសមត្ថភាព ឬជំនាញស្មើគ្នា និង កង្វះការបញ្ជាក់ក្នុងនិយមន័យ និងយន្តការសម្រាប់ដោះស្រាយបញ្ហាបៀតបៀនផ្លូវភេទ។

ប្រជាពលរដ្ឋដែលអាចប្រកបការងារបាន (អាយុពី១៥ទៅ ៦៤ឆ្នាំ) កំពុងតែកើនឡើង ប្រមាណ៣០០,០០០នាក់ជារៀងរាល់ឆ្នាំ[11]។ កំណើនប្រជាសាស្ត្រនេះ បានផ្តល់ឱកាស សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ប៉ុន្តែចំនួនការងារដែលបានបង្កើតនៅមានកម្រិតទាប ។ ដូចនេះ ការបង្កើតការងារសមរម្យសម្រាប់ស្ត្រីនិងបុរស នៅតែជាបញ្ហាប្រឈមដ៏ចម្បង។

ការបង្កើតការងារសម្រាប់អ្នកគ្មានជំនាញ ពិសេសសម្រាប់ស្ត្រីងាយរងគ្រោះដោយសារ មានចំណេះដឹងទាប បើធៀបនឹងបុរស (ធៀបនឹងបុរស និងស្ត្រីក្នុងប្រទេសជិតខាង) នឹង

---

9 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ អង្គការពលកម្មអន្តរជាតិ (ឆ្នាំ២០១២) អង្កេតកម្លាំងពលកម្មនៅកម្ពុជា ភ្នំពេញ កម្ពុជា

10 Ibid

11 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១៣) អង្កេតប្រជាសាស្ត្រចន្លោះជំរឿនកម្ពុជា ភ្នំពេញ កម្ពុជា

មានការប្រឈមយ៉ាងខ្លាំងក្នុងសកលភាវូបនីយកម្ម និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥ ។

យុទ្ធសាស្រ្តបើកចំហការអភិវឌ្ឍន៍ និងការនាំចេញ បានរួមចំណែកក្នុងការបង្កើនការងារក្នុងវិស័យកាត់ដេរ ប៉ុន្តែផលប៉ះពាល់អវិជ្ជមាន នៃវិបត្តិហិរញ្ញវត្ថុពិភពលោក ឆ្នាំ២០០៨-២០០៩ លើការងាររបស់ស្រ្តី តម្រូវឱ្យធ្វើពិពិធកម្ម និងកាត់បន្ថយការពឹងផ្អែកលើតម្រូវការខាងក្រៅ ។

## ស្រ្តីនៅក្នុងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម

*ស្រ្តីមានសក្តានុពលជាច្រើនក្នុងការបង្កើតនិងពង្រីកអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម ប៉ុន្តែមានឧបសគ្គដោយសារលទ្ធភាពទទួលបានធនធាននិងសេវាអភិវឌ្ឍន៍អាជីវកម្មមានកំណត់ រួមទាំងធនធានហិរញ្ញវត្ថុ។ លើសពីនេះ សហគ្រាសរបស់ស្រ្តីភាគច្រើនស្ថិតក្នុងវិស័យឧស្សាហកម្មដែលមានផលិតភាពទាប។*

ប្រទេសកម្ពុជា មានសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ចំនួន ៥០៥.១៣៤ នៅឆ្នាំ ២០១១[12]។ សហគ្រាសទាំងអស់នេះ បានផ្តល់ការងារដល់មនុស្សចំនួន១.៦៧៦.២៦៣ នាក់ ក្នុងនោះបុរសមានចំនួន ៦៥០.១៧៩នាក់(ស្មើនឹង៣៨,៨០ភាគរយ និងស្រ្តី ១.០២៦.០៨៤ (ស្មើនឹង៦១,២០ភាគរយ)។ គ្រប់សហគ្រាសទាំងអស់នេះ ផ្តល់ការងារដល់ស្រ្តីច្រើនជាងបុរស។

មុខជំនួញភាគច្រើនរបស់ស្រ្តី គឺសហគ្រាសខ្នាតមីក្រូ៖ ៥១%នៃសហគ្រាសទាំងនេះមាន សមាជិកតែ១នាក់៥១% រីឯការប្រកបអាជីកម្មដែលមានសមាជិក៤នាក់ ឬក្រោម ៤នាក់មាន៩៦%។ មុខរបររបស់ស្រ្តីភាគច្រើនផ្តុំគ្នាក្នុងផ្នែកឧស្សាហកម្មមួយចំនួនតូច ដូចជាផ្នែកលក់ដុំ និងរាយ ផ្ទះសំណាក់ឬសណ្ឋាគារ និងភោជនីយដ្ឋាន កម្មន្តសាល និងសេវាកម្មផ្សេងទៀត ដែលចំនួនសរុបស្មើនឹង៩៧% នៃមុខជំនួញទាំងអស់ ។

[12] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១១) ជំរឿនសេដ្ឋកិច្ចកម្ពុជា ភ្នំពេញ កម្ពុជា

| ប្រភេទសហគ្រាស | ចំនួនសហគ្រាស | | |
|---|---|---|---|
| | សរុប | បុរសជាម្ចាស់ | ស្ត្រីជាម្ចាស់ |
| ចំនួនសហគ្រាសសរុប | ៥០៥. ១៣៤ | ១៧៦.១២៨ | ៣២៩.០០៦ |
| | ១០០% | ៣៤.៩០% | ៦៥.១០% |
| លក់ដុំ និងរាយ ជួសជុលយានយន្ត | ២៨៩.១៣០ | ៧៣.៥១៦ | ២១៥.៦១៤ |
| | ៥៧,២០% | ១៤,៦០% | ៤២,៧០% |
| សណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន | ៦៩.៥៦៩ | ១៤.៦១២ | ៥៤.៩៥៧ |
| | ១៣,៨០% | ២,៩០% | ១០,៩០% |
| កមន្តសាល | ៧៥.០៣១ | ៣៩.៩៩៨ | ៣៥.០៣៣ |
| | ១៤,៩០% | ៧,៩០% | ៦,៩% |
| ផ្សេងៗ | ៧១.៤០៤ | ៤៨.០០២ | ២៣.៤០២ |
| | ១៤,១០% | ៩,៥០% | ៤,៦០% |

(ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ជម្រឿនសេដ្ឋកិច្ច ឆ្នាំ២០១១)

ស្ត្រីទទួលបានធនធានសម្រាប់ពង្រីកមុខជំនួញនៅមានកម្រិតជាងបុរស។ ស្ត្រីទទួលបានព័ត៌មានតិចតួច រួមទាំងបទបញ្ញត្តិរបស់រាជរដ្ឋាភិបាល (ការចុះបញ្ជី ឯកសារតម្រូវការក្នុងពាណិជ្ជកម្ម) និងការបណ្តុះបណ្តាល។ កង្វះតម្លាភាព និងការតាមដានបទបញ្ញត្តិមុខជំនួញដែលមានស្រាប់ អាចធ្វើឱ្យស្ត្រីជួបនូវផលលំបាក។ សហគ្រាសខ្នាតមីក្រូដែលភាគច្រើនដឹកនាំដោយស្ត្រី ត្រូវរងសម្ពាធពីការបង់ប្រាក់ក្រៅផ្លូវការ។ បទដ្ឋានសង្គមដែលទាក់ទងនឹងតួនាទីស្ត្រី បានរារាំងការចូលរួមរបស់ស្ត្រីក្នុងសមាគម និងបណ្តាញអាជីវកម្ម ព្រមទាំងកម្រិតឱកាសដល់ស្ត្រី ក្នុងការលើកទ្បើងនូវកង្វល់ជាក់លាក់របស់ខ្លួន។



▲ ប្រាក់ខែផ្តល់នូវឱកាសដល់ស្ត្រី រួមទាំងការពុះពារជំនះរាល់ឧបសគ្គនានាផងដែរ។

## ជីវភាពរស់នៅទីជនបទ និងការងារកសិកម្ម

*ការអភិវឌ្ឍន៍វិស័យកសិកម្ម និងជីវភាពរស់នៅតាមជនបទរបស់ស្ត្រី ត្រូវជួបឧបសគ្គដោយសារកង្វះលទ្ធភាព និងកម្មសិទ្ធិ លើធនធាន និងឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុក្នុងពិភពលោក (ទឹកជំនន់ ភាពរាំងស្ងួត និងការកើនឡើង សីតុណ្ហភាព)។ លើសពីនេះ ស្ត្រីធ្វើការងារដែលមិនមានប្រាក់កម្រៃនិងការងារថែទាំផ្សេងៗទៀត ធ្វើឲ្យគេមានពេលវេលានៅសល់តិចតួចសម្រាប់ការងាររកប្រាក់ចំណូល។*

ស្ត្រីដែលមានការងារធ្វើមាន៥៣%នៅទូទាំងប្រទេស និង៦៣%នៅជនបទ ប៉ុន្តែការងាររបស់ពួកគេភាគច្រើនស្ថិតក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានផលិតភាពទាប និងបញ្ជាក់ពីការទទួលផលក្នុងកម្រិតទាបសម្រាប់កម្លាំងពលកម្មស្ត្រី[13]។ វិស័យកសិកម្មរួមចំណែក៣៦% នៃ

[13] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១២) អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ភ្នំពេញ កម្ពុជា

ផលទុនជាតិសរុប (GDP) ប៉ុន្តែមានតែជាង៥០% នៃប្រជាជនដែលមានអាយុពី១៥-៦៤ឆ្នាំ មានការងារធ្វើនិងមានការកើនឡើងតិចតួចជាងវិស័យផ្សេងទៀត នៅទសវត្សរ៍ចុងក្រោយនេះ។

ផលិតកម្មកសិកម្មបានទទួលរងវិបត្តិពីខាងក្រៅតិចជាងវិស័យឧស្សាហកម្ម ហើយក៏ជាវិស័យតែមួយគត់ដែលនៅតែបន្តរីកចម្រើនក្នុងអំឡុងវិបត្តិសេដ្ឋកិច្ចពិភពលោក។ ស្ត្រីនិងបុរសនៅតំបន់ជនបទទំនងជាបញ្ចូលសកម្មភាពសេដ្ឋកិច្ចក្នុងការរកចំណូលសម្រាប់ជីវភាពជាងអ្នកដែលរស់នៅតំបន់ទីក្រុង។ នៅតំបន់ជនបទ ៤៧%នៃស្ត្រី និង៥៣%នៃបុរសមានការងារបន្ទាប់បន្សំ។ ការងារកសិកម្ម ជាទូទៅត្រូវបានបែងចែកទៅតាមភេទ ក្នុងនោះស្ត្រីទទួលខុសជាចម្បងលើការសាប ស្ទូង ដកស្ទូង បោកបែនដោយដៃ និងចិញ្ចឹមសត្វទ្រង់ទ្រាយតូច។ បុរសទទួលខុសត្រូវការងារធំៗ ដូចជាការរៀបចំដី ធារាសាស្ត្រ បោកបែនដោយម៉ាស៊ីន និងចិញ្ចឹមសត្វទ្រង់ទ្រាយធំ។

កសិកម្ម គឺនៅតែជាវិស័យមានការងារលេចធ្លោសម្រាប់ស្ត្រី ក៏ប៉ុន្តែពួកគេទទួលបាននូវធនធាន ដែលចាំបាច់សម្រាប់ផលិតកម្មកសិកម្មនៅមានកំរិតនៅឡើយ។ នៅឆ្នាំ២០០៨ ស្ត្រីជាមេគ្រួសារដែលមានចំនួន២០% នៃគ្រួសារកសិករសរុបមានដីកសិកម្មចំនួន១,១ហិកតា តិចជាងបុរសជាមេគ្រួសារ ដែលមានដីកសិកម្មចំនួន១,៥ហិកតា[14]។ លើសពីនេះទៀត ស្ត្រីដែលរៀបការរួចប្រហែលជាមិនអាចគ្រប់គ្រងដីដែលបានចុះបញ្ជីរួមគ្នាជាមួយស្វាមីបាន ដោយសារស្ត្រីមិនបានចូលរួមជាមួយបុរសនៅក្នុងដំណើរការចុះបញ្ជីដីធ្លី ហើយអាចនឹងបាត់បង់សិទ្ធិកាន់កាប់ដីធ្លីផងដែរ ក្នុងករណីលែងលះ រស់នៅបែកគ្នា និងស្វាមីបោះបង់ចោល[15]។ ការកើនឡើង នៃការគ្មានដី គឺជាមូលហេតុចម្បងនៃភាពងាយរងគ្រោះ។ ស្ត្រីទទួលបានធនធានសំខាន់ៗតិចតួចសម្រាប់លើកកម្ពស់ផលិតភាពកសិកម្ម។ ឧទាហរណ៍ ស្ត្រីដែលទទួលសេវាផ្សព្វផ្សាយកសិកម្មមានត្រឹមតែ១០% ហើយស្ត្រីជាមេគ្រួសារចំនួន៣១% មានលទ្ធភាពទទួលបាននង្គ័លភ្ជួរស្រែធៀបនឹង៤៨%នៃបុរសដែលជាមេគ្រួសារ។

ស្ត្រីមានឧសគ្គច្រើនជាងបុរសនៅក្នុងការរកទីផ្សារទំនិញកសិកម្មដោយសារតែការទទួលខុសត្រូវថែទាំក្រុមគ្រួសារ ការព្រួយបារម្ភផ្នែកសុវត្ថិភាព និងសន្តិសុខនៅពេល

---

[14] Food and Agriculture Organization and National Institute of Statistics (2010) *National Gender Profile of Agricultural Households*. Report based on the 2008 CSES. Phnom Penh.

[15] Food and Agriculture Organization and National Institute of Statistics, 2010, National Gender Profile of Agricultural Households, Report based on the 2008 CSES. Phnom Penh

ដែលធ្វើដំណើរនៅទីកន្លែងសាធារណៈ ការអប់រំផ្នែកហិរញ្ញវត្ថុនៅមានកម្រិតទាប ការបង់ថ្លៃសេវាក្រៅផ្លូវការ ក៏ដូចជាការលំបាកក្នុងការទទួល និងផ្តល់ព័ត៌មាន និងទំនាក់ទំនងជាមួយក្រុមអ្នកលក់ជាដើម។

បម្រែបម្រួលអាកាសធាតុជាសាកល មានជាប់ពាក់ព័ន្ធជាមួយនឹងផ្នែកផ្សេងៗទៀតនៃអាកាសធាតុ ដូចជាគ្រោះទឹកជំនន់ឆ្នាំ២០១១ និងឆ្នាំ២០១៣ បានប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងទៅផលិតកម្មកសិកម្ម ការងារក្នុងវិស័យកសិកម្ម និងគ្រួសារនៅជនបទ។ គ្រួសារកសិករដែលពឹងផ្អែកលើទឹកភ្លៀងងាយទទួលរងនឹងការផ្លាស់ប្តូរអាកាសធាតុ ដែលបណ្តាលឱ្យជីវភាពប្រជាជននៅជនបទមានកង្វះខាត។

បម្រែបម្រួលអាកាសធាតុបង្កឱ្យមានការកើនឡើងនូវហានិភ័យដោយគ្រោះធម្មជាតិ ទឹកជំនន់ និងភាពរាំងស្ងួត ជាពិសេសផ្តល់ផលប៉ះពាល់អវិជ្ជមានលើផលិតកម្មកសិកម្ម និងជីវភាពតាមជនបទ។ ចំណុចនេះអាចបណ្តាលឱ្យមានកំណើន នៃការធ្វើទេសន្តប្រវេសន៍ កំណើនកម្ចីប្រាក់មកប្រើប្រាស់សម្រាប់តម្រូវការចាំបាច់ អត្រាពលកម្មកុមារកើនខ្ពស់ ព្រមទាំងបង្កើនបន្ទុកការងារគ្មានប្រាក់កម្រៃដល់ស្ត្រីថែមទៀត។ មេគ្រួសារជាស្ត្រីអាចនឹងទទួលផលប៉ះពាល់ពីគ្រោះធម្មជាតិខ្លាំង ដោយសារពុំបានទទួលព័ត៌មានអំពីគ្រោះធម្មជាតិ និងការទទួលការប្រឹក្សាយោបល់តិចតួចពីសហគមន៍ និងលទ្ធភាពមានកម្រិតក្នុងការទទួលបានឥណទាន ពេលវេលា និងការធ្វើបម្លាស់ទី។ គ្រោះមហន្តរាយធម្មជាតិទាក់ទងនឹងការផ្លាស់ប្តូរអាកាសធាតុ អាចបង្កើនបន្ទុកការងារគ្មានកម្រៃសម្រាប់ស្ត្រី ដូចជាការស្វែងរកទឹកបរិភោគ និងអុសជាដើម។

សកម្មភាពការងារថែទាំ និងការងារផ្ទះដែលគ្មានប្រាក់កម្រៃរបស់ស្ត្រី និងមូលធនមនុស្សមានកម្រិតទាប គឺជាបញ្ហាដល់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ ស្ត្រី និងក្មេងស្រី បានចូលរួមមួយភាគធំក្នុងការងារថែទាំ និងការងារផ្ទះដែលគ្មានប្រាក់កម្រៃនៅក្នុងគ្រួសារ និងសហគមន៍។ នេះគឺជាការប្រឈមសម្រាប់ពួកគេក្នុងការចូលរួមក្នុងការងារមានប្រាក់កម្រៃ ក៏ដូចជាការអប់រំ និងការបណ្តុះបណ្តាលនានា។ មានការប៉ាន់ប្រមាណថាស្ត្រីចំណាយពេល៣ម៉ោងនិង៣០នាទីរៀងរាល់ថ្ងៃ សម្រាប់ការងារគ្មានប្រាក់ចំណូល និងការងារថែទាំ[16]។ ការងារគ្មានប្រាក់កម្រៃនេះ ឆ្លុះបញ្ចាំងពីអតុល្យភាព ដ៏ធំធេងលើការបែងចែកការងារ និងការធ្វើឲ្យបន្ទុកការងាររបស់ស្ត្រី មានកម្រិតខ្ពស់ជាងបុរស។

---

16 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០០៧) អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ ការប្រើប្រាស់ ពេលវេលា ភ្នំពេញ កម្ពុជា

ទោះបីអត្រានៃភាពក្រីក្រផ្អែកលើប្រាក់ចំណូលមានការថយចុះ ក៏ប៉ុន្តែភាពក្រីក្ររបស់ប្រជាជន ជាពិសេសនៅតំបន់ជនបទនៅតែមានកម្រិតខ្ពស់ ហើយចំនួននៃជនងាយរងគ្រោះកំពុងកើនឡើង។ ការធ្លាក់ចុះនៃអត្រាភាពក្រីក្រ (ផ្អែកលើបន្ទាត់ក្រីក្រថ្នាក់ជាតិ) ពី២៩,៩% នៅឆ្នាំ២០០៨ មកនៅត្រឹម១៩,៨%នៅឆ្នាំ២០១១[17] ចំនួនភាគរយនៃគ្រួសារជាច្រើនបានរំកិលចេញពីបន្ទាត់ភាពក្រីក្រ ប៉ុន្តែនៅមិនទាន់ឃ្លាតឆ្ងាយពីភាពក្រីក្រនៅឡើយ មានន័យថាជាគ្រួសារដែលងាយរងគ្រោះក្នុងវិបត្តិផ្សេងៗ។

ផ្អែកលើមូលដ្ឋានទិន្នន័យបន្ទាត់ភាពក្រីក្រអន្តរជាតិ នៅក្នុងឆ្នាំ២០០៩ មានគ្រួសារក្រីក្រប្រមាណ១៨,៦% ទទួលបានប្រាក់ចំណូល១,២៥ ដុល្លារ ក្នុងមួយថ្ងៃ ( អំណាចទិញ ) និង៤៩,៥%ទទួលបានប្រាក់ចំណូល ២ដុល្លារក្នុងមួយថ្ងៃ នេះបង្ហាញឱ្យឃើញថាប្រជាពលរដ្ឋកម្ពុជាពាក់កណ្តាលស្ថិតក្នុងភាពងាយរងគ្រោះ។ អត្រាភាពក្រីក្រលើប្រាក់ចំណូលធ្លាក់ចុះមិនធានាថាសុខមាលភាពរបស់ស្ត្រី និងក្មេងស្រីបានប្រសើរនោះទេ ប្រសិនបើធនធាន ទាំងនោះមិនបានបែងចែកឱ្យស្មើគ្នានៅក្នុងគ្រួសារ។ កង្វះអាហារូបត្ថម្ភខ្ពស់ និងភាពស្លេកស្លាំងក្នុងចំណោមស្ត្រី រួមជាមួយអំពើហិង្សាក្នុងគ្រួសារ បានបង្ហាញពីភាពរងគ្រោះរបស់ស្ត្រី និងភាពលំបាកក្នុងការទទួលបានធនធាន។ វិបត្តិសេដ្ឋកិច្ចជាបន្ទុកដ៏ធ្ងន់ធ្ងរបន្ថែមទៀតសម្រាប់គ្រួសារអោច និងបណ្តាលឱ្យមានការកើនឡើងនូវអត្រាអំពើហិង្សាលើរាងកាយ ផ្លូវចិត្ត ផ្លូវភេទ និងសេដ្ឋកិច្ចស្ត្រី។

បើប្រៀបធៀបទៅនឹងបុរស ស្ត្រីជួបប្រទះភាពងាយរងគ្រោះដោយវិបត្តិ និងហានិភ័យខ្ពស់ជាង។ ស្ត្រីមិនសូវមានលទ្ធភាពទទួលបានធនធាន និងមានឱកាសតិចតួចក្នុងការរកការងារ ដើម្បីដោះស្រាយវិបត្តិទាំងនោះ។ ប្រភេទនៃហានិភ័យ គឺមានភាពផ្សេងពីគ្នាទៅតាមដំណាក់កាលនៃវដ្តជីវិតរបស់ស្ត្រី។ វិបត្តិហិរញ្ញវត្ថុពិភពលោក ឆ្នាំ២០០៨-២០០៩ បានកាត់បន្ថយកំណើនសេដ្ឋកិច្ច និងការងារ ជាពិសេសក្នុងចំណោមស្ត្រី ហើយជាលទ្ធផលស្ត្រី និងក្មេងស្រីបានផ្លាស់ប្តូរទៅរកការងារ និងការចិញ្ចឹមជីវិតដែលមានប្រាក់កម្រៃទាប និងលក្ខខ័ណ្ឌការងារមិនសូវអំណោយផល។

គ្រួសារដែលរស់នៅតំបន់ជនបទ បានបញ្ជូនក្មេងស្រី និងស្ត្រីវ័យចំណាស់ស្វែងរកការងារធ្វើដើម្បីរកកម្រៃ៖ អត្រាកម្លាំងពលកម្មរបស់ក្មេងស្រីក្នុងវិស័យការងារដែលមាន

[17] Ministry of Planning, General Directorate of Planning (2014) *Poverty Estimate in 2012 in Cambodia*. Available at http://www.mop.gov.kh/Projects/tabid/148/Default.aspx

អាយុចន្លោះពី១៥ឆ្នាំ ដល់១៩ឆ្នាំនៅទីក្រុងភ្នំពេញ កើនឡើងពី៣៦,៥% ទៅ៤០,៦% ក្នុងរវាងឆ្នាំ២០០៨ និងឆ្នាំ២០០៩ ចំណែកអត្រាកម្លាំងពលកម្មរបស់ក្មេងប្រុសដែលមានអាយុពី១៥ឆ្នាំ ដល់១៩ឆ្នាំ ក្នុងវិស័យការងារមានត្រឹមតែ២៦,៣% ដល់ ២៧,២% ។ ករណីខាងលើបញ្ជាក់ថា ក្មេងស្រីបោះបង់ការសិក្សា ដើម្បីស្វែងរកការងារធ្វើ។

អត្រាកម្លាំងពលកម្មរបស់ស្ត្រីវ័យចំណាស់ក្នុងវិស័យការងារដែលមានអាយុចន្លោះពី៥៥ឆ្នាំ ដល់អាយុ៦៤ឆ្នាំ មានការកើនឡើងនៅតំបន់ជនបទពី៧០% ទៅ៧៦,៨% រវាងឆ្នាំ២០០៨ និង២០០៩ ចំណែកឯបុរសវ័យចំណាស់មានរហូតដល់ ៨៨,៦% និង៨៨,៥% រវាងឆ្នាំ២០០៨និងឆ្នាំ២០០៩[18]។ វិបត្តិសេដ្ឋកិច្ចមានផលប៉ះពាល់ផ្នែកយេនឌ័របន្ថែមទៀតដល់ក្មេងស្រី និងស្ត្រីងាយរងគ្រោះ ៣៩%នៃគ្រួសារដែលបានចូលរួមក្នុងការស្រាវជ្រាវ បានរាយការណ៍ថា ម្តាយនិងបងស្រីបរិភោគតិចតួច ដើម្បីទុកអាហារឱ្យសមាជិកផ្សេងៗក្នុងគ្រួសារ។ គ្រួសារក្រីក្រ និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ទំនងជាខ្វះប្រាក់ដើម្បីចំណាយទៅលើអាហារ និងសុខភាព។

## ស្ត្រីពលករទេសន្តប្រវេសន៍ក្នុងនិងក្រៅប្រទេស

*ស្ត្រីកំពុងធ្វើទេសន្តប្រវេសន៍ស្វែងរកការងារកាន់តែច្រើនពីជនបទមកទីក្រុង និងទៅក្រៅប្រទេស។ ជាទូទៅពួកគេជួបហានិភ័យច្រើនជាងបុរសរួមទាំងអំពើហិង្សាលើរាងកាយ។*

ចំនួនស្ត្រីមានការកើនឡើងក្នុងការធ្វើទេសន្តប្រវេសន៍ ដើម្បីរកការងារធ្វើទាំងក្នុងប្រទេស និងក្រៅប្រទេស។ ក្នុងឆ្នាំ ២០១៣ ប្រជាជនកម្ពុជា ២៩% (ប្រហែល ៤,២ លាននាក់) បានធ្វើចំណាកស្រុក។ ៥០%នៃពលករទេសន្តប្រវេសន៍ក្នុងប្រទេស គឺជាស្ត្រី[19]។ ពលករចំណាកស្រុកពីជនបទមកទីក្រុង មានចំនួនប្រមាណពីរភាគបីនៃចំនួនពលករចំណាកស្រុកសរុប ។ ស្ត្រីធ្វើការនៅរោងចក្រកាត់ដេរ អាជីវកម្មខ្នាតតូច និងឧស្សាហកម្មបំរើសេវា[20]។ ពលករចំណាកស្រុកទៅក្រៅប្រទេសមានចំនួនមួយភាគបី។ នៅឆ្នាំ២០១០ មានពលករទេសន្តប្រវេសន៍ស្របច្បាប់ ៨៥ភាគរយ ធ្វើការងារនៅប្រទេសម៉ាឡេស៊ី (ភាគ

---

[18] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (២០០៩) អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា តារាងពលកម្មទី៤ ភ្នំពេញ កម្ពុជា

[19] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១៣) អង្កេតប្រជាសាស្ត្រចន្លោះជំរឿនកម្ពុជា ភ្នំពេញ កម្ពុជា

[20] National Institute of Statistics, Ministry of Planning (2012) Migration in Cambodia: Report of the Cambodian Rural Urban Migration Project (CRUMP). Phnom Penh, Cambodia.

ច្រើនធ្វើការងារបម្រើតាមផ្ទះ) និង៤៤ភាគរយនៅប្រទេសថៃ[21]។ ប៉ុន្តែការហាមឃាត់ជាបណ្តោះអាសន្នក្នុងការធ្វើទេសន្តប្រវេសន៍ទៅកាន់ប្រទេសម៉ាឡេស៊ី សម្រាប់ការងារបម្រើក្នុងផ្ទះដោយមានប្រាក់កម្រៃនៅតែបន្តចាប់តាំងពីឆ្នាំ២០១១ដូចនេះទើបចំនួនពលករស្ត្រីទៅធ្វើការប្រទេសម៉ាឡេស៊ីមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់។ អត្ថប្រយោជន៍នៃការធ្វើទេសន្តប្រវេសន៍ ត្រូវបានកាត់បន្ថយយ៉ាងខ្លាំងដោយសារប្រាក់កម្រៃទាប លក្ខខ័ណ្ឌការងារមិនល្អ ការជ្រើសរើសអ្នកមិនទាន់គ្រប់ អាយុ ការអនុវត្តន៍ការជ្រើសរើសមិនស្របច្បាប់ និងការកេងប្រវ័ញ្ច ព្រមទាំងទទួលរងហានិភ័យនៃការជួញដូរនិងរំលោភបំពាន។ បើទោះបីជាប្រាក់កម្រៃពីការងារកាត់ដេរមានកម្រិតទាបជាង២ស្សាហកម្មដទៃ ក៏កម្មការិនីចំនួន២ភាគ៣ បានផ្ញើប្រាក់ទៅក្រុមគ្រួសារបានដែរ ដែលគិតជាមធ្យមគឺ១ភាគ៤នៃប្រាក់ចំណូលសរុប។

## មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីមិនទាន់ត្រូវបានប្រើប្រាស់ពេញលេញនូវសក្តានុពលដែលខ្លួនមាននៅឡើយ

នាពេលបច្ចុប្បន្ន មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី គឺជាមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដែលស្ថិតនៅក្រោមមន្ទីរកិច្ចការនារីនៃក្រសួងកិច្ចការនារី។ មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីផ្តល់កម្មវិធីបណ្តុះបណ្តាលតាមប្រពៃណី ដូចជាសិប្បកម្ម កាត់សក់ និងការកែច្នៃម្ហូបអាហារ។ មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីមានមន្ត្រីសរុបចំនួន១៣៨នាក់។ ជារៀងរាល់ឆ្នាំសិក្ខាកាមចំនួន១,៩០០នាក់បញ្ចប់ការសិក្សានៅមជ្ឈមណ្ឌលប៉ុន្តែសេវាបណ្តុះបណ្តាលនេះមានផលប៉ះពាល់មានកម្រិត និងមិនសូវមានស្ត្រីពីតំបន់ជនបទដាច់មកចូលរួមទេ។ នេះបណ្តាលមកពីរចនាសម្ព័ន្ធ និងថវិការបស់មជ្ឈមណ្ឌល មិនអនុញ្ញាតឲ្យមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីផ្តល់សេវាផ្សេងៗក្រៅពីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេ។

ក្នុងផ្នែកមួយនៃយុទ្ធសាស្ត្រលើកកំពស់ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ក្រសួងកិច្ចការនារីមានគោលបំណងប្រើប្រាស់បណ្តាញមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដើម្បីបង្ហាញគំរូផ្តួចផ្តើមថ្មីៗសម្រាប់សហការជាមួយវិស័យឯកជន ជាពិសេសសហគ្រិន "បៃតង" និងសហគ្រាសសង្គម។ ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ ក្រសួងកិច្ចការនារីត្រូវបញ្ជាក់ពីជម្រើសស្របច្បាប់នានា ដើម្បីបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ក្រុមហ៊ុន

[21] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (២០១៤) គោលនយោបាយទេសន្តប្រវេសន៍ ភ្នំពេញ កម្ពុជា (forthcoming)

សាធារណៈ និងគំរូកិច្ចសន្យានានានៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ។ បន្ទាប់ពីបានកំណត់ដំណោះស្រាយ កិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នារវាងក្រសួងកិច្ចការនារី អង្គការក្រៅរដ្ឋាភិបាល និងសហគ្រិន " បៃតង " និងសហគ្រាសសង្គម អាចត្រូវបានរៀបចំសម្រាប់បង្កើតឱកាសការងារ និងរកប្រាក់ចំណូលសម្រាប់ស្ត្រី។

គំរូសក្តានុពលក្នុងកិច្ចសហការថ្មីៗ មានគោលបំណងផ្គូរផ្គងជំនាញ និងសមត្ថភាពរបស់ស្ត្រី ទៅនឹងតម្រូវការការងារទីផ្សារ និងវិស័យសហគ្រាសខ្នាតមីក្រូ តូចនិងមធ្យម។ ការនេះនឹងធ្វើឲ្យស្ត្រីកាន់តែមានលទ្ធភាពទទួលបានការងារ នៅក្នុងវិស័យឯកជន និងបង្កើនចំនួនស្ត្រីចាប់ផ្តើម និងពង្រីកអាជីវកម្មរបស់ខ្លួន។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងកិច្ចការនារីមានបំណងសហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីកាត់បន្ថយការផ្តល់វគ្គបណ្តុះបណ្តាលដូចគ្នា ។

## អនុសាសន៍សម្រាប់គោលនយោបាយ

### ១. បង្កើតនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ជាមួយដៃគូពាក់ព័ន្ធ

| | |
|---|---|
| ក. ធ្វើឱ្យមានលក្ខណៈជាប្រព័ន្ធនូវយន្តការលើកកំពស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ស្តីពីការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី រួមទាំងយុទ្ធសាស្ត្រផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី និងក្របខ័ណ្ឌជំរុញគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ខ. គាំទ្រក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការរៀបចំគោលនយោបាយជាតិស្តីពីការងារ និងដាក់បញ្ចូលគោលដៅការងារដែលឆ្លើយតបនឹងយេនឌ័រ រួមទាំងការលុបបំបាត់ការរើងអើងលើស្ត្រីភេទ និងក្រុមងាយរងគ្រោះដទៃទៀត និងតាមដានការអនុវត្តន៍ ។ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| គ. ស្វែងរកការគាំទ្រមតិឲ្យមានការតាមដានផលប៉ះពាល់ឆ្លើយតបនឹងយេនឌ័រសម្រាប់ការចំណាយលើការបង្កើតការងារនៅតាមក្រសួងពាក់ព័ន្ធ | ក្រសួងកិច្ចការនារី |
| ឃ.ក្រសួងកិច្ចការនារីគួរកំណត់ជម្រើសកិច្ចសន្យានានា សម្រាប់កិច្ចសហការជាមួយ វិស័យឯកជន (សហគ្រាសសង្គម អង្គការក្រៅរដ្ឋាភិបាល) | ក្រសួងកិច្ចការនារី |

### ២.ពង្រីកឱកាសការងារមានប្រាក់កម្រៃសម្រាប់ស្ត្រី រួមទាំងក្រុមងាយរងគ្រោះ និងកែលម្អលក្ខខ័ណ្ឌការងារ

| | |
|---|---|
| ក. កិច្ចសហការរវាងក្រសួងកិច្ចការនារី ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទាក់ទងនឹងការផ្តល់កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដោយផ្តោតជាសំខាន់លើស្ត្រីមានលក្ខណៈជាប្រព័ន្ធ។ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | |
|---|---|
| ខ. សហការជាមួយអ្នកពាក់ព័ន្ធនានានៅក្នុងទីផ្សារការងារ (អង្គការពលកម្មអន្តរជាតិ សមាគមរោងចក្រកាត់ដេរ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន) ក្នុងការស្វែងរកការគាំទ្រមតិលើការរើសអើងលើស្ត្រីនៅកន្លែងការងារ និងបង្ហាញស្តង់ដារការងារ កិច្ចការពារសង្គម ការដោះស្រាយវិវាទ ។ល។ រួមទាំងការកែសំរួលច្បាប់និងបទបញ្ញត្តិនានាដើម្បីលើកកម្ពស់សមភាពយេនឌ័រ។ | អង្គការពលកម្មអន្តរជាតិ សមាគមរោងចក្រកាត់ដេរ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន |
| គ. ស្វែងរកការគាំទ្រលើការកែសម្រួល និងបង្កើនធនធានហិរញ្ញវត្ថុសម្រាប់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី សម្រាប់វិនិយោគលើការលើកកំពស់ការអភិវឌ្ឍន៍ជំនាញថ្មីៗ រួមទាំងសហគ្រិនភាព និងការតាមដាន និងវាយតម្លៃ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

### ៣. សហគ្រាសខ្នាតមីក្រូ តូច និងមធ្យមរបស់ស្ត្រីត្រូវបានបង្កើត និងកែលម្អ

| | |
|---|---|
| ក. សហការជាមួយក្រសួងពាក់ព័ន្ធ ក្នុងការលើកកំពស់ការបង្កើត និងការប្រតិបត្តិរបស់សមាគមសហគ្រិនស្ត្រី ក្រុមស្ត្រីអ្នកផលិត និងលើកទឹកចិត្តស្ត្រីចូលរួមបណ្តាញអាជីវកម្មនានា ដូចជាវេទិការាជរដ្ឋាភិបាលរវាងវិស័យសាធារណៈ និងវិស័យឯកជន។ | ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| ខ. តាមរយៈភាពជាដៃគូជាមួយស្ថាប័នសាធារណៈ និងឯកជនដែលផ្តល់សេវាអភិវឌ្ឍន៍អាជីវកម្ម រួមទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្រសួងកិច្ចការនារីលើកកំពស់ការយល់ដឹងពីសេវាអភិវឌ្ឍន៍អាជីវកម្មសំខាន់ៗ សំរាប់សហគ្រិនស្ត្រីខ្នាតមីក្រូ តូច និងមធ្យម រួមទាំងសេវាហិរញ្ញវត្ថុ ការអប់រំពីហិរញ្ញវត្ថុ និងព័ត៌មាននិងចំណេះដឹងទាក់ទងនឹងអាជីវកម្ម។ | ក្រសួងពាណិជ្ជកម្ម ស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី |

| | |
|---|---|
| គ. ស្វែងរកការគាំទ្រលើការកែសម្រួល និងបង្កើនធនធានហិរញ្ញវត្ថុសម្រាប់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី សម្រាប់វិនិយោគលើការលើកកំពស់និងអភិវឌ្ឍន៍សហគ្រិនភាព ខ្នាតមីក្រូ តូច និងមធ្យមសម្រាប់ស្ត្រី | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

### ៤. ស្ត្រីក្រីក្រ និងក្រុមងាយរងគ្រោះនៅជនបទវិនិយោគលើការអភិវឌ្ឍន៍ជីវភាពរស់នៅ

| | |
|---|---|
| ក. តាមដានការអនុវត្តន៍ច្បាប់ដីធ្លី ទាក់ទងនឹងឧបសគ្គដាក់លាក់របស់ស្ត្រីនិងក្រុមងាយរងគ្រោះ ក្នុងការទទួលបានកម្មសិទ្ធ និងសិទ្ធដីធ្លី | ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ |
| ខ. គាំទ្រស្ត្រីក្នុងការធ្វើពិពិធកម្ម ពាណិជ្ជូបនីយកម្ម លើវិស័យកសិកម្ម និងបង្កើនសកម្មភាពសេដ្ឋកិច្ច ដែលមិនទាក់ទងនឹងកសិកម្ម | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| គ. ដាក់បញ្ចូលការលើកកំពស់បំណិនជីវិតសម្រាប់ស្ត្រី នៅក្នុងនីតិវិធីរៀបចំផែនការរបស់មជ្ឈមណ្ឌល ក្រសួងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ឃ. លើកកម្ពស់ការយល់ដឹងសាធារណៈអំពីតុល្យភាពរវាងការងារ និងជីវិតសម្រាប់ ស្ត្រី និងតម្រូវការកែលំអហេដ្ឋារចនាសម្ព័ន្ធនៅតាមសហគម (លទ្ធភាពទទួលបានទឹក សាលារៀន អនាម័យ ។ល។) | ក្រសួងកិច្ចការនារី |
| ង. ធ្វើឲ្យប្រាកដថាយន្តការកំណត់អត្តសញ្ញាណជនក្រីក្ររបស់ក្រសួងផែនការ ឆ្លើយតបនឹងយេនឌ័រ | ក្រសួងផែនការ |

### ៥. ស្ត្រីទទួលបានផលប្រយោជន៍ពីការងារចំណាកស្រុក ទាំងក្នុងនិងក្រៅប្រទេស ហើយឧបសគ្គនានាត្រូវបានកាត់បន្ថយ

| | |
|---|---|
| ក. ផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិស្តីពីពលករក្នុងស្រុក និងអនុសញ្ញា ស្តីពីការការពារ ពលករទេសន្តប្រវេសន៍ និងគ្រួសាររបស់គេ។ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | |
|---|---|
| ខ. គាំទ្រការបង្កើត និងការអនុវត្តន៍អនុស្សារណៈយោគយល់ទ្វេភាគី ដើម្បីការពារសិទ្ធិនិងសុវត្ថិភាពរបស់ស្ត្រីពលករទេសន្តប្រវេសន៍ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| គ. គាំទ្រការតាមដានទីភ្នាក់ងារជ្រើសរើសពលករទេសន្តប្រវេសន៍ ដែលគ្រប់គ្រងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងពង្រឹងយន្តការសម្រាប់ទទួល និងដាក់ពាក្យបណ្តឹងថ្មីៗ រួមទាំងសេវារបស់មជ្ឈមណ្ឌលធនធានទេសន្តប្រវេសន៍ ទាក់ទងនឹងការជួយស្ត្រីចំណាកស្រុកអភិវឌ្ឍន៍ជីវភាព បន្ទាប់ពីការធ្វើទេសន្តប្រវេសន៍។ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ឃ. សម្របសម្រួលជាមួយគណៈកម្មការជាតិលុបបំបាត់ការជួញដូរនិងការកេងប្រវ័ញ្ចពលករទេសន្តប្រវេសន៍។ | NCCT |

# សេចក្តីថ្លែងអំណរគុណ

ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជាត្រូវបានចងក្រងឡើងនៅក្រោមការដឹកនាំ និងសម្រប សម្រួលដោយក្រសួងកិច្ចការនារី ដោយមានការគាំទ្រនិងរួមចំណែកពីក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ ក្រសួងកិច្ចការនារីសូមថ្លែងអំណរគុណ ជូនចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលបានចូលរួមចំណែកក្នុងការរៀបចំ ឯកសារនេះ ដូចតទៅ៖

**ក្រុមការងាររៀបចំការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា** ទទួលខុសត្រូវលើដំណើរការ រៀប ចំឯកសារទាំងមូល ក្រោមការដឹកនាំរបស់ លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។ ក្រុមការងារមានលោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការ ជាប្រធាន និងគាំទ្របច្ចេកទេសដោយផ្ទាល់ពីលោកជំទាវ កេត សំអាត ទីប្រឹក្សាជាន់ខ្ពស់ ក្រសួងកិច្ចការនារី លោកជំទាវ គីម ស៊ីផាត់ អគ្គនាយិកា ក្រសួងកិច្ចការនារី និង លោក ថៃ ឈុនហាក់អគ្គនាយករងក្រសួងកិច្ចការនារីលោកស្រី ញាណ សុចិត្រា ប្រធាននាយកដ្ឋាន សមភាពយេនឌ័រ លោកស្រី តែ វួចលីម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ និងសមាជិក ផ្សេងៗទៀតមកពីនាយកដ្ឋានបច្ចេកទេសនានាចំណុះក្រសួងកិច្ចការនារី។ ក្រុមការងារមាន ការគាំទ្រផ្នែកបច្ចេកទេសពីគម្រោង **ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ** (PGEIII) ដែលមាន លោកស្រី Mia Hyun ជាទីប្រឹក្សាជាន់ខ្ពស់ប្រចាំក្រសួងកិច្ចការនារី ជាអ្នកសម្របសម្រួល ទូទៅ គាំទ្រដោយក្រុមអ្នកជំនាញតាមវិស័យរបស់គម្រោង រួមមាន លោកស្រី ឌី ម៉ានី លោក ប៉ែន បូរី លោកស្រី ហេង សិលទិ លោក ឈន ថាវរិទ្ធិ៍ និង លោក គឹម សុពណ៌។ **ក្រុមការងារបច្ចេកទេសយេនឌ័រ** (TWG-G) បានផ្តល់ជាវេទិកាដ៏សំខាន់ក្នុងការពិគ្រោះ យោបល់ជាមួយអ្នកពាក់ព័ន្ធ និងក្រុមអ្នកជួយកែសម្រួល (peer reviewers) ដែលជាអ្នក ជំនាញមកពីក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល បានជួយ ពិនិត្យ ឡើងវិញលើសេចក្តីព្រាងតាមជំនាញពាក់ព័ន្ធ។ បច្ចេកទេសទាក់ទងនឹងរូបភាព ការរចនា និងសម្ភារៈសម្រាប់ផ្សព្វផ្សាយផ្តល់ដោយ Good Morning Beautiful ។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី៣៖** ជំពូកនេះដឹកនាំរៀបចំដោយលោកជំទាវ ច័ន្ទ សូរិយ៍ និងចងក្រងសេចក្តីព្រាងដោយលោកស្រីសាស្ត្រាចារ្យ Fiona MacPhail ដែលជាទី ប្រឹក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងផ្តល់ជាតុចូលនិងកែសម្រួលដោយលោកស្រី

ប៊ុនឈិត វាសនា ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចនៃក្រសួងកិច្ចការនារី និងក្រុមការងារ រួមមាន លោកស្រី សុត ស៊ីថុន លោកស្រី ហេង សិលទិ កញ្ញា ធឿន សមនា និងលោក Udo Gartner ។ ធាតុចូលស្តីពីទេសន្តប្រវេសន៍ផ្តល់ដោយលោកស្រី Jenna Holliday (UN WOMEN) និងធាតុចូលពាក់ព័ន្ធនឹងវិស័យកសិកម្មផ្តល់ដោយលោក Emmanuel Santoyo Rio ទីប្រឹក្សារបស់ធនាគារពិភពលោក។ លោកស្រី Karin Schelzig (ADB) ជាអ្នកផ្តល់ធាតុចូលផ្នែកបច្ចេកទេសកែសម្រួល និងពិនិត្យជារួមលើខ្លឹមសារ។ លោកស្រី ជា ចាន់ឌី ដែលជាអ្នកឯកទេសយេនឌ័ររបស់ ADB ផ្តល់ការគាំទ្រក្នុងការសិក្សាស្រាវជ្រាវ ។

ក្រសួងកិច្ចការនារី
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ហ្វាក់ : (+៨៥៥) ២៣ ៨៨០ ៧៣៧
អ៊ីម៉ែល : mwa@online.com.kh
វេបសាយ : www.mowa.gov.kh
ហ្វេសប៊ុក : www.facebook.com/mowa.gov.kh